ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣៣*៤៤

លេខៈ ៣៦៨

ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧

## សាលដីកា

លេខៈ ៩៨

ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៥

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៥ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២-លោក ស៊ិន ឌីម ជាចៅក្រម

៣-លោក ប្រាក់ គឹមសាន ជាចៅក្រម

៤-លោក ជីវ កេង ជាចៅក្រម

៥-លោក ឈឹម ស៊ីផល ជាចៅក្រម

៦-លោក សោម សិរីវឌ្ឍ ជាចៅក្រម

៧-លោក ប៉ែន សារឿន ជាចៅក្រម

៨-លោក គង់ ភីរុន ជាចៅក្រម

៩-លោក យស់ សួខឿន ជាចៅក្រម

ក្រឡាបញ្ជី

លោក **ម៉ៅ សុធណ្ណ**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

លោក ប៉ែន ស៊ិន ជាចៅក្រមរបាយការណ៍(ស្លាប់)

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៦៣៣ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤៧ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **ង៉ែត ឈួន** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៧២ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅក្រុមទី៧ មណ្ឌល១ សង្កាត់លេខ២ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ។

ចុងចម្លើយឈ្មោះ**ប៊ិត សាត**(ស្លាប់) ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកមន្ទីរពេទ្យក្រុងព្រះសីហនុ ទីលំនៅ៦មណ្ឌល១ សង្កាត់២ ខ័ណ្ឌមិត្តភាព ក្រុង ព្រះសីហនុ ។ ឪពុកឈ្មោះប៊ិត ផៃ "រ" ម្តាយឈ្មោះសេង សំ "រ" ។

ចុងចម្លើយឈ្មោះ **ខែក ច័ន្ទសុត្ថាណា** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកសុខាភិបាលក្រុងព្រះសីហនុ ទីលំនៅក្រុមទី៧ មណ្ឌល១ សង្កាត់លេខ២ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។ ឪពុកឈ្មោះខែក លាន"ស" ម្តាយឈ្មោះទិត ច័ន្ទលាត"ស"។

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារសំណងអន្តរាយបណ្តាលពីអគ្គីភ័យ

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ៣៩៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៧ របស់ឈ្មោះង៉ែត ឈួន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៣៣ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ នៃសាលដីកា ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ៣៩៧ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៧ របស់ឈ្មោះខែក ច័ន្ទសុត្ថាណា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៣៣ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦៨ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១១-០៧-១៩៩២ របស់ឈ្មោះ ង៉ែត ឈួន ប្តឹងពីឈ្មោះ ប៊ិត សាត និងនាងខែក ច័ន្ទសុត្ថាណា ថា កាលពីថ្ងៃទី០៩-០៧-១៩៩២ ចុងចម្លើយទាំងពីរនាក់បានបង្កឱ្យមានអគ្គីភ័យឆាបឆេះរាលដាលបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ខ្លួន ដូចជាផ្ទះឈើ ជញ្ជាំងថ្មប្រក់ហ្វីប្រូមួយខ្នង ថ្នាំពេទ្យ ខោអាវ មុងភួយ គ្រែតុទូ ឆេះខ្ទេចខ្ទីគ្មាន សេសសល់អ្វីឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៣១០ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៩៣ របស់តុលាការក្រុងព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-សំរេចបដិសេធពាក្យបណ្តឹងរបស់លោកស្រីឌុច អៀម ចោលជាអសារបង់ ។

២-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៣-ឱ្យលោកប៊ិត សាត និងលោកស្រី ខែក ច័ន្ទសុត្ថាណា ជាចុងចម្លើយបានរួច ផុតពីសំណងរដ្ឋប្បវេណីចាប់តាំងពីថ្ងៃនេះតទៅ ។

៤-ទុកសិទ្ធិឱ្យដើមចោទ និងចុងចម្លើយប្ដឹងជាបទព្រហ្មទណ្ឌនិង បទរដ្ឋប្បវេណី ដរាបណារកឃើញអ្នកបង្កអគ្គីភ័យកាលពីថ្ងៃទី០៩-០៧-១៩៩២ ចាប់តាំងពីថ្ងៃនេះតទៅ ។

៥-សំរេចរឹបអូសប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្លឹងចំនួន១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះចំនួន ៥.០០០៛ បូករួម៧.០០០៛។

ប្រាក់នេះបានកាត់យកពីប្រាក់ចំនួន ៧.០០០៛ ដែលដើមចោទបានបង់ទុករួចហើយ ។

សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូភាគី និង បើកផ្លូវឧទ្ធរណ៍ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៩៣ របស់ឈ្មោះង៉ែតឈួន ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៣០ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៩៣ របស់តុលាការក្រុងព្រះសីហនុ ត្រង់ចំណុចសាលក្រមទាំងស្រុង ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១០៦ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះង៉ែត ឈួន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-សំរេចបដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៣០ ចុះថ្ងៃទី២៦-១១-១៩៩៣ របស់តុលាការក្រុងព្រះសីហនុចោលជាអសារបង់ ។

៣-សំរេចឱ្យឈ្មោះប៊ិត សាត និងខែក ច័ន្ទសុត្ថាណា ចេញសោហ៊ុយសងការខូចខាតទៅឱ្យឈ្មោះង៉ែត ឈួន ជាប្រាក់ចំនួន ៤០.០០០(បួនម៉ឺន)បាត ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ដែលឈ្មោះង៉ែត-ឈួន បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដីនិងពន្ធហ្លឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ១០.០០០៛ ។

កាលបើហួសបណ្ដឹងសាទុក្ខ បង្គាប់ឱ្យឈ្មោះប៊ិត សាត និង ខែក ច័ន្ទ សុត្ថាណា សងប្រាក់១៣.០០០៛ ឱ្យទៅង៉ែត ឈួន វិញ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រ១%លើចំនួនប្រាក់៤ម៉ឺនបាត ប្រាក់ពន្ធនេះ គឺជាប្រយោជន៍ដល់ថវិការដ្ឋ៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី សំរេចបើក

ផ្លូវសាទុក្ខរយៈពេល២ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះតទៅ ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៦ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៤ របស់ឈ្មោះខែក ច័ន្ទសុត្ថាណា និង ប៊ិត សាត ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១០៦ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៨៨ ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ១៩៩៦ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ ៥៦ ចុះថ្ងៃទី២៥-១១-៩៤ របស់ឈ្មោះប៊ិត សាត និងនាង ខែក ច័ន្ទសុត្ថាណា ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១០៦ ចុះថ្ងៃទី២១-១១-៩៤របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២៨៧ចុះថ្ងៃទី១០-១០-៩៥ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលឈ្មោះប៊ិត សាត និង នាងខែក ច័ន្ទសុត្ថាណា ជាចុងចម្លើយបានបង់ទុកនៅតុលាការកំពូលចំនួន ១៩.០០០៛ គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងការប្រគល់ដីកាកោះ១៥.០០០៛ សរុប ១៩.០០០៛ ហើយតំរូវឱ្យឈ្មោះង៉ែត ឈួន សងប្រាក់ ១៩.០០០៛ ទៅឈ្មោះប៊ិត សាត និងនាងខែកច័ន្ទសុត្ថាណា វិញ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី២៦ ខែមិនា ឆ្នាំ១៩៩៦ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦៣៣ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ ៤៧ ចុះថ្ងៃទី២៧-៦-១៩៩៦របស់សាលាឧទ្ធរណ៍ដោយអំណាចសាលដីកាលេខ ៨៨ ចុះថ្ងៃទី២៦-៣-១៩៩៦ របស់តុលាការកំពូលឡើងវិញ ។

២-បង្គាប់ឲ្យឈ្មោះប៊ិត សាត និង ឈ្មោះខែក ច័ន្ទសុត្ថាណា រួមគ្នាសងការខូចខាតចំនួន ២៥.០០០បាត "ពីរម៉ឺនប្រាំពាន់បាត" ស្មើ ២៣៧៥.០០០រ "ពីរលានបីសែនប្រាំពីរម៉ឺនប្រាំពាន់រៀល" ទៅឲ្យឈ្មោះង៉ែត ឈួន ។ សំណូមពរលើសពីនេះបដិសេធចោល ។

៣-បង្គាប់ឲ្យឈ្មោះប៊ិត សាត និង ឈ្មោះខែក ច័ន្ទសុត្ថាណា រួមគ្នាបង់ពន្ធសមាមាត្រមួយភាគរយ លើតម្លៃប្រាក់សំណងក្នុងចំនុចទី២ ។ ប្រាក់នេះត្រូវដាក់ចូលថវិការដ្ឋ៨០% និងដាក់ក្នុងហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៤-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឈ្មោះង៉ែតឈួន ឈ្មោះខែក ច័ន្ទសុត្ថាណា កំបាំងមុខឈ្មោះប៊ិត សាត ។

សំរេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ៣៨៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៧ របស់ឈ្មោះង៉ែត ឈួន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៣៣ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ នៃសាលដីកា ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ៣៩៧ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៧ របស់ឈ្មោះខែក ច័ន្ទសុត្ថាណា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៣៣ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៧ របស់ឈ្មោះប៊ិត សាត និង ខែក ច័ន្ទសុត្ថាណា ។

បានឃើញសារណាតបចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់ឈ្មោះង៉ែត ឈួន ។

បានឃើញសារណាការពារចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់ឈ្មោះង៉ែត ឈួន ។

បានឃើញសារណារតបចុះថ្ងៃទី២៣ខែកុម្ភៈឆ្នាំ១៩៩៨ របស់ឈ្មោះខែកច័ន្ទសុត្ថាណា ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ៦៣៣ ចុះថ្ងៃទី២១-១០-១៩៩៧ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ និងគតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះង៉ែត ឈួន នាពេលសវនាការថា : ខ្លួនឈប់ទាមទារសំណងអ្វីទាំងអស់ ទុករាប់អានគ្នា ។

បានស្តាប់ចម្លើយរបស់ឈ្មោះខែក ច័ន្ទសុត្តាណា នាពេលសវនាការថា: ខ្លួនគ្មានលទ្ធភាពសងទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយលោកង៉ែត ឈួន និងអ្នកស្រីខែក ច័ន្ទ សុត្តាណា
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២ លេខ ៣៨៦ ចុះថ្ងៃទី២១-១០-១៩៩៧ របស់លោកង៉ែត ឈួន និងបណ្តឹងសាទុក្ខលេខ ៣៩៧ ចុះថ្ងៃទី២១-១០-១៩៩៧ របស់អ្នកស្រីខែក ច័ន្ទ សុត្តាណា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះដល់អង្គសេចក្តីបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលមានអានុភាពផងដែរ ក្នុងរឿងរដ្ឋប្បវេណី ។

- យល់ឃើញថា នៅពេលសវនាការនេះ លោកង៉ែត ឈួន ជាដើមចោទ បានលើកឡើងថា ឈ្មោះប៊ិត សាត បានទទួលមរណភាពទៅហើយ លោកឈប់ទាមទារសំណងពីឈ្មោះនេះទៀតហើយ ។ រីឯអ្នកស្រីខែក ច័ន្ទសុត្តាណា សព្វថ្ងៃខ្លួនបានរាប់អានគ្នាវិញហើយ ដូច្នេះលោកក៏ឈប់ទាមទារសំណងពីអ្នកស្រីខែក ច័ន្ទសុត្តាណាដែរ ។ ឆ្លើយតបវិញអ្នកស្រីខែកច័ន្ទសុត្តាណា បានលើកឡើងថា អ្នកស្រីពិតជាបានស្រុះស្រួលជាមួយលោកង៉ែត ឈួន ប្រាកដមែន ដោយលោកង៉ែត ឈួន បញ្ជាក់ថា លោកឈប់ទាមទារសំណងពីអ្នកស្រីហើយ ។

ដូច្នេះតុលាការកំពូលគប្បីទទួលស្គាល់ការព្រមព្រៀងរបស់គូភាគីនៅពេលសវនាការនេះ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខលោកង៉ែត ឈួន**

**និង អ្នកស្រី ខែក ច័ន្ទសុត្តាណា**

១-ទទួលស្គាល់ការព្រមព្រៀងរបស់គូភាគីនៅពេលសវនាការនេះទុកជាត្រឹមត្រូវតាមច្បាប់។

២-អនុញ្ញាតិឱ្យលោក ង៉ែត ឈួន ដកពាក្យបណ្តឹងវិញ និងសំរេចឱ្យអ្នកស្រីខែក ច័ន្ទសុត្តាណា រួចខ្លួនពីកាតព្វកិច្ចសំណង ។

៣-ចំណាយសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦៨ ចុះថ្ងៃទី២៧-១១-១៩៩៧របស់តុលាការកំពូលចេញពីបញ្ជីក្តី ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៥។